# ក្រុមសីលធម៌សម្រាប់ការស្រាវជ្រាវ ដែលទាក់ទងនឹងមនុស្សរបស់
Johns Hopkins Bloomberg School of Publich Health (JHSPH)
# ឯកសារណែនាំសម្រាប់ការបណ្តុះបណ្តាលនៅតំបន់សិក្សា

គោលបំណងនៃឯកសារណែនាំនេះ គឺប្រើប្រាស់ដើម្បីជាឧបករណ៍ជំនួយដល់ការបណ្តុះបណ្តាលសម្រាប់បុគ្គលទាំងឡាយណាដែលនឹង "ពាក់ព័ន្ធ" ក្នុងគម្រោងសិក្សាស្រាវជ្រាវ ឬអន្តរាគមន៍ ដែលទាក់ទងនឹងមនុស្ស។ ជាពិសេស ឯកសារនេះ មានគោលដៅណែនាំដល់អ្នកអង្កេតតាមដានរបស់សកលវិទ្យាល័យ Johns Hopkins ដែលទទួលខុសត្រូវក្នុងការបណ្តុះបណ្តាលដល់ក្រុមសិក្សាស្រាវជ្រាវដែលនឹងត្រូវ (១) សុំការអនុញ្ញាតយល់ព្រមដោយស្ម័គ្រចិត្តពីសំណាក់អ្នកចូលរួមនៅក្នុងសិក្សាស្រាវជ្រាវ ឬ (២) ប្រមូលទិន្នន័យព័ត៌មានពីអ្នកចូលរួមតាមរយៈការសម្ភាសន៍បុគ្គលម្នាក់ៗ ឬជាក្រុម ការធ្វើតេស្ត ការពិនិត្យរាងកាយ ឬនីតិវិធីផ្សេងទៀតដែលពាក់ព័ន្ធដោយផ្ទាល់នឹងអ្នកចូលរួម។ បុគ្គលទាំងនេះហៅថា "អ្នកប្រមូលទិន្នន័យ"។ ខ្លឹមសារ និងកម្រិតនៃការប្រើប្រាស់ភាសានៅក្នុងឯកសារណែនាំនេះ ត្រូវបានប្រើប្រាស់ពាក្យពេចន៍យ៉ាងជាក់លាក់ដើម្បីជួយអ្នកអង្កេតតាមដាន ប្រាប់ពួកគេឲ្យដឹងអំពីគោលការណ៍ជាមូលដ្ឋាននៃការស្រាវជ្រាវ និងឥរិយាបទដែលសមស្របតាមគោលការណ៍ក្នុងការប្រមូលទិន្នន័យ។ យើងសូមលើកទឹកចិត្តដល់អ្នកប្រើប្រាស់ឯកសារណែនាំនេះ ហើយដែលបកប្រែទៅជាភាសាក្នុងស្រុក សូមមេត្តាដាក់ឯកសារបកប្រែទាំងនោះ (ដោយមានភ្ជាប់ជាមួយនូវវិញ្ញាបនបត្របញ្ជាក់គុណភាពរបស់អ្នកបកប្រែ) មកកាន់ការិយាល័យរបស់យើងតាមរយៈអ៊ីម៉ែល (irboffice@jhsph.edu) ដើម្បីអាចឲ្យយើងយកឯកសារបកប្រែទាំងនោះចែកជូនអ្នកអង្កេតតាមដានផ្សេងទៀតផងដែរ។

## តារាងមាតិកា


១. ក្រុមសីលធម៌នៃការទំនាក់ទំនងទៅវិញទៅមកជាមួយអ្នកចូលរួម

ក. តួនាទីរបស់អ្នកប្រមូលទិន្នន័យ

ខ. សារសំខាន់នៃការគោរព

គ. ការចូលរួមដោយស្ម័គ្រចិត្ត

ឃ. ការយល់ព្រមក្រោយពីបានទទួលព័ត៌មានសព្វគ្រប់

ង. ក្រុមមនុស្សដែលងាយនឹងរងគ្រោះ

ច. ភាពឯកជនផ្ទាល់ខ្លួន

ឆ. ការការពារព័ត៌មានផ្ទាល់ខ្លួន

ជ. ការឆ្លើយតបចំពោះសំណួររបស់អ្នកចូលរួម

២. ភាពត្រឹមត្រូវនៃទិន្នន័យ

ក. ការគោរពតាមវិទ្យាសាស្ត្រនៃការសិក្សា

ខ. ការប្រមូល ការកត់ត្រា និងការរក្សាទុកទិន្នន័យសិក្សា

គ. ការដកចេញពីនីតិវិធីសិក្សា





សិទ្ធិថតចម្លងឆ្នាំ២០១០ ដោយសាកលវិទ្យាល័យ Johns Hopkins។ រក្សាសិទ្ធិគ្រប់យ៉ាង។



ហ្វឺស-ក្លាស FIRST-CLASS In Pursuit of Speed and Quality

ក្រុមហ៊ុន **ហ្វឺស-ក្លាស សឹលូសិន អិលធីឌី** ចុះបញ្ជីពាណិជ្ជកម្មក្រោមលេខ Co. 13113/09P នៅក្រសួងពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា

#៨ មហាវិថីព្រះសីហនុ ភ្នំពេញ កម្ពុជា។ ទូរស័ព្ទ/ទូរសារ៖ (៨៥៥) ២៣ ២១៤ ១៤២ - ទូរស័ព្ទដៃ៖ ០១២ ៥២៥ ៧៨៩ / ០១៨ ៩០១ ៣៧៧ | info@firstclass.com.kh | www.firstclass.com.kh

ក្រុមហ៊ុនសូមបញ្ជាក់ថាសំណៅបកប្រែនេះពិតជាត្រឹមត្រូវតាមឯកសារភ្ជាប់ចំពោះគ្រប់ខ្លឹមសារមួយៗនៃឯកសារ ប្រាកដមែន ។ សេចក្តីបញ្ជាក់នេះពុំបានកំណត់អំពីយថាភាពនៃច្បាប់ដើម ឬអំពីភាពត្រឹមត្រូវនៃព័ត៌មានដែលបាន រៀបរាប់នៅក្នុងសំណៅនេះឡើយ ។ *(USEmbassy2013)*

ភ្នំពេញ ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៣

**លឹម គ្រុយ អគ្គនាយក**

**ក្រុមហ៊ុន ហ្វឺស ក្លាស សឹលូសិន អិលធីឌី**

## ១. ក្រមសីលធម៌ នៃការទំនាក់ទំនងទៅវិញទៅមកជាមួយអ្នកចូលរួម

### ក. តួនាទីរបស់អ្នកប្រមូលទិន្នន័យ

បុគ្គលដែលប្រមូលទិន្នន័យជំនួសឲ្យក្រុមសិក្សាស្រាវជ្រាវគឺជា "អ្នកតំណាង" សម្រាប់ការសិក្សាស្រាវជ្រាវនេះ។ ពេលខ្លះ អ្នកប្រមូលទិន្នន័យជាសមាជិកនៅក្នុងក្រុមសិក្សាស្រាវជ្រាវដែលជាគោលដៅសម្រាប់ធ្វើការទំនាក់ទំនងរាល់ចម្ងល់ទាក់ទងនឹងការសិក្សាស្រាវជ្រាវពីសំណាក់អ្នកចូលរួម។ មនុស្សដែលធ្វើការទំនាក់ទំនងជាមួយអ្នកប្រមូលទិន្នន័យ នឹងមានចំណាប់អារម្មណ៍ល្អ ឬមិនល្អអំពីការសិក្សាស្រាវជ្រាវដោយអាស្រ័យលើឥរិយាបទបង្ហាញផ្ទាល់របស់អ្នកប្រមូលទិន្នន័យ។

អ្នកប្រមូលទិន្នន័យត្រូវទទួលខុសត្រូវដើម្បីធ្វើឲ្យប្រាកដថា ព័ត៌មានដែលប្រមូលបានសម្រាប់ការ សិក្សាស្រាវជ្រាវនេះ គឺទទួលបានពីអ្នកចូលរួមទាំងឡាយដែលយល់ច្បាស់អំពីអ្វីដែលពួកគាត់នឹងយល់ព្រមធ្វើទៅតាមនីតិវិធី និងការស្នើសុំ។ ជាងនេះទៅទៀត អ្នកប្រមូលទិន្នន័យត្រូវធានាចំពោះព័ត៌មាន ដែលខ្លួនបានប្រមូល និងកត់ត្រាទុកឲ្យមានសុក្រិតភាព ព្រមទាំងការពារមិនឲ្យបាត់បង់ផងដែរ បើមិនដូច្នោះទេ គោលបំណងនៃការសិក្សាស្រាវជ្រាវនេះ នឹងមិនអាចសម្រេចបានឡើយ។ ដើម្បីទទួលបានជោគជ័យ អ្នកប្រមូលទិន្នន័យត្រូវអនុវត្តដោយយកចិត្តទុកដាក់តាមគម្រោង នីតិវិធីសម្រាប់ដំណើរការសិក្សាស្រាវជ្រាវ និងនីតិវិធីផ្សេងទៀតដែលមានទំនាក់ទំនងជាមួយអ្នកចូលរួម។

### ខ. ការគោរព

សមាជិកម្នាក់ៗនៅក្នុងក្រុមសិក្សាស្រាវជ្រាវ ត្រូវតែបង្ហាញនូវការគោរពដូចខាងក្រោម៖

- គោលដៅរបស់គម្រោងសិក្សាស្រាវជ្រាវ
- អ្នកដឹកនាំគម្រោង
- អ្នកចូលរួមក្នុងគម្រោងសិក្សាស្រាវជ្រាវម្នាក់ៗ
- សហគមន៍អ្នកចូលរួម និង
- ទិន្នន័យប្រមូលបានដែលនឹងជួយសម្រេចគោលបំណងរបស់គម្រោង

គម្រោងសិក្សាបែបវិទ្យាសាស្ត្រដែលនឹងត្រូវលើកយកមកធ្វើការសិក្សាស្រាវជ្រាវ មានសក្តានុពលចំពោះការផ្តល់អត្ថប្រយោជន៍ដល់សហគមន៍ ប៉ុន្តែលុះត្រាតែក្រុមសិក្សាស្រាវជ្រាវមានសមត្ថភាពបំពេញរាល់ការងារដែលបម្រើឲ្យការសិក្សានេះបានគ្រប់ជ្រុងជ្រោយប៉ុណ្ណោះ។

សមាជិកក្រុមស្រាវជ្រាវនីមួយៗ ត្រូវធ្វើការទំនាក់ទំនងជាមួយសមាជិកសហគមន៍អ្នកចូលរួមទាំងអស់ដោយមានការគោរព រួមមាន វប្បធម៌ ភេទ អាយុ ស្ថានភាពសង្គម សាសនា និងចរិតលក្ខណៈ ខុសប្លែកផ្សេងៗគ្នា ព្រមទាំងសិទ្ធិក្នុងការសួរសំណួររបស់ពួកគាត់ផងដែរ។ អ្នកចូលរួមមិនចាំបាច់ជួយ ក្រុមសិក្សាស្រាវជ្រាវ ដោយត្រូវតែចូលរួមឡើយ ហើយជាងនេះទៅទៀត ក៏មិនចាំបាច់ធ្វើដូច្នោះដែរ ប្រសិនបើ ក្រុមសិក្សាស្រាវជ្រាវ មិនគោរពសិទ្ធិពួកគាត់ក្នុងការនិយាយថា "ព្រម" ឬ "មិនព្រម" ឬសិទ្ធិក្នុងការទទួលបានភាពស្មោះត្រង់ និងព័ត៌មានពិតប្រាកដពីគ្រប់សមាជិកនៃក្រុមសិក្សាស្រាវជ្រាវ។

អ្នកប្រមូលទិន្នន័យត្រូវប្រាប់អ្នកចូលរួមម្នាក់ៗឲ្យដឹងអំពីសារសំខាន់នៃគោលបំណងសិក្សាស្រាវជ្រាវតាមរយៈការប្រមូលទិន្នន័យប្រកបដោយវិជ្ជាជីវៈ និងការគោរព។

ឧទាហរណ៍៖


សិទ្ធិថតចម្លងឆ្នាំ២០១០ ដោយសាកលវិទ្យាល័យ Johns Hopkins។ រក្សាសិទ្ធិគ្រប់យ៉ាង។

ក្រុមហ៊ុន **ហ្វឹស-ក្លាស សឹលូសិន អិលធីឌី** ចុះបញ្ជីពាណិជ្ជកម្មក្រោមលេខ Co. 13113/09P នៅក្រសួងពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា
#៨ មហាវិថីព្រះសីហនុ ភ្នំពេញ កម្ពុជា។ ទូរស័ព្ទ/ទូរសារ៖ (៨៥៥) ២៣ ២១៤ ១៤២ - ទូរស័ព្ទដៃ៖ ០១២ ៩២៥ ៧៤៩ / ០១៨ ៩០១ ៣៧៧ | info@firstclass.com.kh | www.firstclass.com.kh
ក្រុមហ៊ុនសូមបញ្ជាក់ថាសំណៅបកប្រែនេះពិតជាត្រឹមត្រូវតាមឯកសារភ្ជាប់ចំពោះគ្រប់ខ្លឹមសារមួយដែលមាន ... ភ្នំពេញ ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៣
ប្រាកដមែន ។ សេចក្តីបញ្ជាក់នេះពុំបានកំណត់អំពីយថាភាពនៃច្បាប់ដើម ឬអំពីភាពត្រឹមត្រូវនៃព័ត៌មានដែលបាន
រៀបរាប់នៅក្នុងសំណៅនេះឡើយ ។ *(USEmbassy2013)*
**លឹម ក្រូយ អគ្គនាយក**
**ក្រុមហ៊ុន ហ្វឹស-ក្លាស សឹលូសិន អិលធីឌី**

- ជានិច្ចកាល ត្រូវគួរសមចំពោះអ្នកចូលរួម ទោះជាពួកគាត់យល់ព្រម ឬមិនយល់ព្រមចូលរួមក្នុងការសិក្សាស្រាវជ្រាវក៏ដោយ។
- ប្រសិនបើអ្នកប្រមូលទិន្នន័យសួរសំណួរដល់អ្នកចូលរួម ត្រូវសួរឲ្យច្បាស់លាស់។
- កត់ត្រាទិន្នន័យនៅក្នុងសន្លឹកប្រមូលទិន្នន័យឲ្យមានសណ្តាប់ធ្នាប់ និងច្បាស់លាស់។
- ប្រសិនបើអ្នកចូលរួមសួរសំណួរអ្វីមួយ អ្នកប្រមូលទិន្នន័យត្រូវផ្តល់ចម្លើយឲ្យបានត្រឹមត្រូវ។ ផ្ទុយទៅវិញប្រសិនបើអ្នកប្រមូលព័ត៌មានមិនដឹងពីចម្លើយទេ ប៉ុន្តែអាចរកចម្លើយពីប្រធានរបស់ខ្លួននោះ ត្រូវប្រាប់អ្នកចូលរួមថាអ្នកនឹងសួរសំណួរនោះទៅប្រធាន ហើយនឹងផ្តល់ចម្លើយដល់ពួកគាត់វិញបន្ទាប់ពីទទួលបានចម្លើយនោះ។
- ថ្លែងអំណរគុណដល់អ្នកចូលរួមនៅពេលពួកគាត់បានបញ្ចប់តាមនីតិវិធីសិក្សា។

គ. ការចូលរួមដោយស្ម័គ្រចិត្ត

បុគ្គលម្នាក់ៗមិនមែនសុទ្ធតែត្រូវឲ្យចូលរួមក្នុងគម្រោងសិក្សាស្រាវជ្រាវនេះឡើយ។ ប្រសិនបើការសិក្សាស្រាវជ្រាវមានរួមបញ្ចូល ដំណើរការនៃការយល់ព្រមក្រោយពីបានទទួលព័ត៌មានសព្វគ្រប់ នោះអ្នកចូលរួមម្នាក់ៗ មានសិទ្ធិបដិសេធមិនស្តាប់ការពន្យល់អំពីការសិក្សា និងមិនចូលរួមបាន។ ទោះបីជាអ្នកណាម្នាក់បានចូលរួមក្នុងការសិក្សាស្រាវជ្រាវហើយក៏ដោយ អ្នកនោះក៏អាចបដិសេធមិនឆ្លើយសំណួរជាក់លាក់ណាមួយក្នុងការអង្កេត ឬក្នុងកម្រងសំណួរ បដិសេធមិនផ្តល់សំណាកវិភាគ ឬបដិសេធមិនធ្វើតេស្ត និងអាចសម្រេចចិត្តដកខ្លួនចេញពីការសិក្សាស្រាវជ្រាវនេះបានគ្រប់ពេលវេលាទាំងអស់។

សមាជិកនៃក្រុមសិក្សាស្រាវជ្រាវដែលជាអ្នកស្នើសុំការយល់ព្រមពីអ្នកចូលរួម មានតួនាទីធ្វើឲ្យប្រាកដថាអ្នកចូលរួមម្នាក់ៗយល់អំពីគោលបំណងនៃការសិក្សាស្រាវជ្រាវ និងពិតជាយល់ព្រមចូលរួមការសិក្សាស្រាវជ្រាវប្រាកដមែន ហើយមិនមែនជាការចូលរួមដោយសារតែពួកគាត់មានការភ័យខ្លាច ឬទទួលអារម្មណ៍ថាត្រូវបានបង្ខំឲ្យចូលរួមឡើយ។

ឃ. ការយល់ព្រមក្រោយពីបានទទួលព័ត៌មានសព្វគ្រប់

ការផ្តល់ព័ត៌មានត្រឹមត្រូវ និងជាក់ស្តែងដល់អ្នកដែលត្រូវចូលរួមក្នុងការសិក្សាស្រាវជ្រាវនេះ គឺជាផ្នែកមួយដ៏មានសារសំខាន់នៃការសិក្សាស្រាវជ្រាវដែលទាក់ទងនឹងមនុស្ស។ ការយល់ព្រមក្រោយពីបានទទួលព័ត៌មានសព្វគ្រប់គឺជាដំណើរជាប់បន្តមួយ ដែលចាប់ផ្តើមដោយសមាជិកក្រុមសិក្សាស្រាវជ្រាវដោយពន្យល់អំពីការសិក្សាស្រាវជ្រាវដល់អ្នកចូលរួម។

ការយល់ព្រមក្រោយពីបានទទួលព័ត៌មានសព្វគ្រប់ មិនបញ្ចប់ដោយអ្នកចូលរួមចុះហត្ថលេខាលើទម្រង់យល់ព្រម និងការយល់ព្រមចូលរួមក្នុងការសិក្សាឡើយ។ ដំណើរការនៃការយល់ព្រមក្រោយពីបានទទួលព័ត៌មានសព្វគ្រប់ មានជាប់បន្តនៅក្នុងការសិក្សាទាំងមូល។ ឧទាហរណ៍ ដំណើរការនេះអាចកើតមាននៅគ្រប់ពេលដែលអ្នកប្រមូលទិន្នន័យ និងអ្នកចូលរួមទំនាក់ទំនងគ្នា។ វាមិនមែនជា "ការយល់ព្រម" ពិតប្រាកដឡើយ ប្រសិនបើអ្នកចូលរួមមិនបានយល់ច្បាស់អំពីសំណួរដែលកំពុងសួរពួកគាត់នោះ។ ក្រុមអង្កេតតាមដានកំណត់ទុកជាមុននូវព័ត៌មាន "គ្រប់គ្រាន់" និងវិធីដែលត្រូវផ្តល់ព័ត៌មានទាំងនោះ។ ការងាររបស់អ្នកផ្តល់ព័ត៌មានដើម្បីទទួលការយល់ព្រម ត្រូវបង្ហាញព័ត៌មានអំពីការសិក្សាស្រាវជ្រាវដល់អ្នកដែល


សិទ្ធិថតចម្លងឆ្នាំ២០១០ ដោយសាកលវិទ្យាល័យ Johns Hopkins។ រក្សាសិទ្ធិគ្រប់យ៉ាង។

ក្រុមហ៊ុន ហ្វឺស-ក្លាស សឺលូសិន អិលធីឌី ចុះបញ្ជីពាណិជ្ជកម្មក្រោមលេខ Co. 13113/09P នៅក្រសួងពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា
#៨ មហាវិថីព្រះសីហនុ ភ្នំពេញ កម្ពុជា។ ទូរស័ព្ទ/ទូរសារ៖ (៨៥៥) ២៣ ២១៤ ១៤២ - ទូរស័ព្ទដៃ៖ ០១២ ៩៦៥ ៧៨៩ / ០១៨ ៩០១ ៣៣៧ | info@firstclass.com.kh | www.firstclass.com.kh
ក្រុមហ៊ុនសូមបញ្ជាក់ថាសំណៅបកប្រែនេះពិតជាត្រឹមត្រូវតាមឯកសារភ្ជាប់ចំពោះគ្រប់ខ្លឹមសារមូលដ្ឋានទាំងអស់ ប្រាកដមែន ។ សេចក្តីបញ្ជាក់នេះពុំបានកំណត់អំពីយថាភាពនៃច្បាប់ដើម ឬអំពីភាពត្រឹមត្រូវនៃព័ត៌មានដែលបានរៀបរាប់នៅក្នុងសំណៅនេះឡើយ ។ (USEmbassy2013)
ភ្នំពេញ ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៣
លឹម គ្រួស អគ្គនាយក
ក្រុមហ៊ុន ហ្វឺស-ក្លាស សឺលូសិន អិលធីឌី

នឹងត្រូវចូលរួមដោយប្រើភាសាងាយយល់ និងតាមវិធីដែលបង្ហាញឲ្យងាយយល់ដឹងអំពីគោលបំណង បែបបទ ហានិភ័យដែលអាចកើតឡើង និងអត្ថប្រយោជន៍នៃការសិក្សាស្រាវជ្រាវនេះ។ ភាសា និងរបៀបទំនាក់ទំនងគ្នាគួរតែធ្វើឲ្យអ្នកចូលរួមអាចនឹងងាយយល់បាន។ គួរផ្តល់ពេលវេលាគ្រប់គ្រាន់សម្រាប់ការពិភាក្សាទាំងនោះ ដើម្បីឲ្យអ្នកចូលរួមអាចសួរសំណួរ និងគិតអំពីការសម្រេចចិត្តថាតើខ្លួនត្រូវចូលរួម ឬមិនចូលរួមក្នុងការសិក្សាស្រាវជ្រាវនេះ។

ជួនកាលការសាកសួរអ្នកចូលរួមម្តងម្កាល អំពីការយល់ដឹងរបស់គាត់មានសារៈសំខាន់ណាស់ ដើម្បីបញ្ជាក់ថាតើអ្នកចូលរួមនៅតែបន្តយល់ដឹងអំពីអ្វីដែលការសិក្សាស្រាវជ្រាវនេះកំពុងសិក្សា ឬអ្វីខ្លះដែលពាក់ព័ន្ធនឹងការសិក្សានេះ។ សមាជិកនៃក្រុមសិក្សាស្រាវជ្រាវដែលជាអ្នកស្នើសុំការយល់ព្រមពីអ្នកចូលរួមអាចត្រូវសួរសំណួរដល់អ្នកចូលរួមដើម្បីពិនិត្យថាតើអ្នកចូលរួមបានរៀនសូត្រអំពីអ្វីខ្លះ និងថាតើអ្នកចូលរួមមានការយល់ដឹងត្រឹមត្រូវដែរឬយ៉ាងណា។ សមាជិកនៃក្រុមសិក្សាស្រាវជ្រាវក៏គួរដឹងពីភាសាកាយវិការរបស់អ្នកចូលរួម ពីព្រោះពេលខ្លះកាយវិការរបស់ពួកគាត់មើលទៅអាចមិនស្រួល ឬច្របូកច្របល់ក្នុងចិត្ត ប៉ុន្តែមិនបាននិយាយចេញឡើយ។ ប្រសិនបើសង្កេតមើលឃើញការឆ្លើយតបទាំងនេះ សមាជិកនៃក្រុមសិក្សាស្រាវជ្រាវគួរជូនដំណឹងដល់ប្រធានរបស់ខ្លួនដើម្បីសុំការណែនាំបន្ថែម។

ង. ក្រុមមនុស្សដែលងាយនឹងរងគ្រោះ

មនុស្សមួយចំនួនត្រូវការការយកចិត្តទុកដាក់ និងការថែទាំបន្ថែមនៅពេលស្នើសុំឲ្យចូលរួមក្នុងការសិក្សាស្រាវជ្រាវ ដោយសារពួកគេស្ថិតក្នុងស្ថានភាពដែលធ្វើឲ្យខ្លួនមានការលំបាកយល់អំពីព័ត៌មាន ដែលបានប្រាប់ និងផ្តល់ការយល់ព្រមក្រោយពីបានទទួលព័ត៌មានសព្វគ្រប់។ ឧទាហរណ៍ កុមារត្រូវការ "ការការពារ" បន្ថែម។ ដូច្នេះហើយវាមានសារសំខាន់ណាស់ដែលឪពុកម្តាយត្រូវធ្វើការសម្រេចចិត្តឲ្យបានច្បាស់លាស់សម្រាប់កុមារទាំងនេះ។ មនុស្សពេញវ័យដែលមានជំងឺវិកលចរិកមិនអាចយល់អំពីអ្វី ដែលអ្នកកំពុងស្នើសុំឲ្យខ្លួនធ្វើឡើយ។ ផែនការសិក្សាស្រាវជ្រាវ និងនីតិវិធីសម្រាប់ដំណើរការសិក្សាស្រាវជ្រាវដែលបង្កើតដោយអ្នកអង្កេតតាមដាន គួរប្រាប់អ្នកថាតើត្រូវធ្វើយ៉ាងណាចំពោះអ្នកវិកលចរិកទាំងនោះ ប្រសិនបើពួកគាត់ត្រូវបានដាក់បញ្ចូលក្នុងការសិក្សាស្រាវជ្រាវ។ សមាជិកនៃក្រុមសិក្សាស្រាវជ្រាវត្រូវប្រុងប្រយ័ត្នបំផុត ដោយអនុវត្តទៅតាមគោលការណ៍នៅពេលចុះឈ្មោះក្រុមមនុស្សដែលងាយនឹងរងគ្រោះ ពីព្រោះភាគច្រើនពួកគាត់មិនអាចធ្វើការសម្រេចចិត្តដោយខ្លួនឯងបានឡើយ។ ប្រសិនបើ ការសិក្សានឹងដាក់បញ្ចូលមនុស្សដែលមិនអាចធ្វើការសម្រេចចិត្តដោយខ្លួនឯងបានន វាចាំបាច់ត្រូវមានការយល់ព្រមពីអ្នកថែទាំ ឬអ្នកតំណាងត្រឹមត្រូវផ្សេងទៀត។

ច. ភាពឯកជនផ្ទាល់ខ្លួន

អ្នកចូលរួមនីមួយៗមានសិទ្ធិទទួលបានភាពឯកជនដែលក្រុមស្រាវជ្រាវត្រូវយល់ដឹង និងគោរពផងដែរ។ ទោះបីជាវប្បធម៌មិនត្រូវបានលើកកម្ពស់ ឬជាទូទៅត្រូវបានផ្តល់ការទទួលស្គាល់អំពី "ភាពឯកជន" ក៏ដោយ សិទ្ធិទទួលបានភាពឯកជន គឺជាកិច្ចការដ៏សំខាន់ដែលត្រូវការពារឲ្យបានទូលំទូលាយតាមដែលអាចធ្វើទៅបាន។ ឧទាហរណ៍៖ អាចជាទំនៀមទម្លាប់មួយដែលមនុស្សម្នាក់មិនអាចចូលទៅក្នុងគេហដ្ឋានរបស់មនុស្សម្នាក់ផ្សេងទៀតដោយពុំមានការអនុញ្ញាតឡើយ។ ក្រុមសិក្សាត្រូវគោរពតាមទំនៀមទម្លាប់នេះ។ ឧទាហរណ៍៖ ការចុះទស្សនៈកិច្ចរបស់អ្នកប្រមូលទិន្នន័យទៅកាន់គេហដ្ឋានរបស់អ្នកណាម្នាក់អាចទាក់ទាញអ្នកផ្សេងមកឈរមើលជាមួយ ហើយវត្តមានរបស់អ្នកទាំងនោះអាចនឹងបង្វែរចំណាប់អារម្មណ៍របស់


សិទ្ធិថតចម្លងឆ្នាំ២០១០ ដោយសាកលវិទ្យាល័យ Johns Hopkins។ រក្សាសិទ្ធិគ្រប់យ៉ាង។

ក្រុមហ៊ុន **ហ្វឺស-ក្លាស សឹលូសិន អិលធីឌី** ចុះបញ្ជីពាណិជ្ជកម្មក្រោមលេខ Co. 13113/09P នៅក្រសួងពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា
#៨ មហាវិថីព្រះសីហនុ ភ្នំពេញ កម្ពុជា។ ទូរស័ព្ទ/ទូរសារ៖ (៨៥៥) ២៣ ២១៤ ១៤២ - ទូរស័ព្ទដៃ៖ ០១២ ៥២៥ ៧៨៩ / ០១៨ ៩០១ ៣៧៧ | info@firstclass.com.kh | www.firstclass.com.kh
ក្រុមហ៊ុនសូមបញ្ជាក់ថាសំណៅបកប្រែនេះពិតជាត្រឹមត្រូវតាមឯកសារភ្ជាប់ចំពោះគ្រប់ខ្លឹមសារមូលដ្ឋានទាំងអស់ ប្រាកដមែន ។ សេចក្តីបញ្ជាក់នេះពុំបានកំណត់អំពីយថាភាពនៃច្បាប់ដើម ឬអំពីភាពត្រឹមត្រូវនៃព័ត៌មានដែលបានរៀបរាប់នៅក្នុងសំណៅនេះឡើយ ។ *(USEmbassy2013)*
ភ្នំពេញ ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៣
**លឹម គ្រុយ អគ្គនាយក**
**ក្រុមហ៊ុន ហ្វឺស-ក្លាស សឹលូសិន អិលធីឌី**

អ្នកប្រមូលព័ត៌មាន និងអ្នកចូលរួមចេញពីការផ្តោតអារម្មណ៍ទៅលើដំណើរការសំខាន់ៗនៃការប្រមូលទិន្នន័យ។ ក្រុមសិក្សាស្រាវជ្រាវត្រូវចូលរួមដោះស្រាយ និងកាត់បន្ថយបញ្ហាទាំងនេះឲ្យនៅតិចបំផុត។ នៅពេលអ្នកប្រមូលទិន្នន័យស្នើសុំឲ្យអ្នកចូលរួមប្រាប់រឿងឯកជនចំពោះសំណើនេះ អ្នកប្រមូលទិន្នន័យត្រូវប្រាកដថាអ្នកឆ្លើយសំណួរស្ថិតនៅក្នុងគេហដ្ឋានរបស់គាត់ ពោលគឺមិនមែននៅកន្លែងសាធារណៈឡើយ។

សមាជិកក្រុមស្រាវជ្រាវក៏ត្រូវតែគោរពភាពឯកជនផ្ទាល់ខ្លួនរបស់អ្នកចូលរួមផងដែរ ដោយមិនត្រូវធ្វើឲ្យពួកគាត់ទទួលភាពអាម៉ាស់ ឬមិនស្រណុកក្នុងចិត្តដោយសារតែរឿងមិនចាំបាច់ផ្ទាល់ខ្លួនរបស់ពួកគាត់ឡើយ។ ការសម្ភាសន៍ដែលពាក់ព័ន្ធជាមួយនឹងព័ត៌មានសម្ងាត់ផ្ទាល់ខ្លួន គួរធ្វើឡើងនៅកន្លែងដែលមនុស្សផ្សេងទៀតមិនអាចស្តាប់ឮសំណួរ ឬចម្លើយបានឡើយ។ ហើយការពិនិត្យរាងកាយរឹតតែមិនគួរធ្វើនៅកន្លែងមនុស្សផ្សេងទៀតអាចមើលឃើញបានឡើយ។ ជាមួយគ្នានេះផងដែរ មានកិច្ចការមួយចំនួនដែលត្រូវចាត់ទុកថាជារឿង "ឯកជន" ដូចជាសកម្មភាពផ្លូវភេទ សុខភាពផ្ទាល់ខ្លួន ឬទស្សនៈនានាដែលមនុស្សម្នាក់មិនចង់និយាយជាសាធារណៈ។

ឆ. ការការពារព័ត៌មានផ្ទាល់ខ្លួន

នៅពេលអ្នកចូលរួមក្នុងការសិក្សាបង្ហាញអំពីព័ត៌មានផ្ទាល់ខ្លួនដល់អ្នកប្រមូលទិន្នន័យ អ្នកចូលរួមប្រឈមមុខនឹងហានិភ័យខ្ពស់ ដោយព័ត៌មានសម្ងាត់របស់ខ្លួនអាចត្រូវបានបញ្ចេញ "ជាសាធារណៈ"។ នោះហើយជាការដែលអ្នកចូលរួមបានប្រឈមនឹងការបាត់បង់ការសម្ងាត់ផ្ទាល់ខ្លួន។ ហានិភ័យ ពោលគឺប្រសិនបើមនុស្សណាម្នាក់ទៀតនៅក្រៅការសិក្សានេះដឹងអំពីព័ត៌មានឯកជនទាំងនេះ រឿងអាក្រក់អាចនឹងកើតឡើងដល់អ្នកចូលរួមដូចជា ភាពអាម៉ាស់មុខ បាត់បង់ការងារ បញ្ហាផ្លូវច្បាប់ ឬដល់ការរស់នៅក្នុងសង្គមរបស់គាត់ទៀតផង។ ក្រុមស្រាវជ្រាវត្រូវតែទទួលខុសត្រូវចំពោះការការពារអ្នកចូលរួមមិនឲ្យមានបញ្ហាទាំងនោះកើតមានឡើងបានឡើយ។

បន្ទាប់ពីអ្នកចូលរួមក្នុងសិក្សាបានផ្តល់ព័ត៌មានរួចរាល់ហើយ ព័ត៌មានផ្ទាល់ខ្លួនទាំងនោះត្រូវរក្សាទុកឲ្យមានសុវត្ថិភាព។ មិនមានមនុស្សណាម្នាក់ដែលអាចមើល ឬមានសិទ្ធិប្រើប្រាស់ពិត័មាននេះដោយគ្មានការអនុញ្ញាតឡើយ។ ប្រសិនបើព័ត៌មានទាំងនោះត្រូវបានសរសេរលើក្រដាស ក្រដាសនោះត្រូវមានការការពាររហូតដល់បានរក្សាទុកក្នុងទូរចាក់សោរ។ មានតែបុគ្គលិកសិក្សាស្រាវជ្រាវដែលទទួលបានការអនុញ្ញាតពីអ្នកអង្កេតតាមដានក្នុងការចាត់ចែងព័ត៌មានប៉ុណ្ណោះដែលអាចមើល និងរៀបចំព័ត៌មានទាំងនោះបាន។ ប្រសិនបើព័ត៌មានសិក្សាជាលក្ខណៈអេឡិចត្រូនិក ត្រូវចាត់វិធានការចាំបាច់ទាំងអស់ដើម្បីប្រាកដថាពុំមានមនុស្សណាម្នាក់ដែលមិនបានទទួលការអនុញ្ញាត អាចមើលព័ត៌មានសម្ងាត់នោះឡើយ។

ពេលខ្លះលេខកូដសិក្សាចោះៗ ត្រូវបានប្រើប្រាស់ក្នុងការកំណត់ទិន្នន័យដើម្បីមិនឲ្យនរណាម្នាក់ដឹងថាទិន្នន័យសម្ងាត់ទាំងនោះជារបស់អ្នកចូលរួមណាម្នាក់បានឡើយ។ ឯកសារទាំងឡាយណាមានកំណត់លេខកូដ និងឈ្មោះរបស់អ្នកចូលរួម ត្រូវរក្សាទុកក្នុងទូរចាក់សោរឲ្យមានសុវត្ថិភាព។ ត្រូវអនុវត្តន៍ទៅតាមផែនការស្រាវជ្រាវ និងឯកសារណែនាំដើម្បីធានាថាទិន្នន័យសិក្សាត្រូវបានការពារយ៉ាងពិតប្រាកដដូចដែលមានចែងនៅក្នុងឯកសារណែនាំរបស់គម្រោងសិក្សា។


សិទ្ធិថតចម្លងឆ្នាំ២០១០ ដោយសាកលវិទ្យាល័យ Johns Hopkins។ រក្សាសិទ្ធិគ្រប់យ៉ាង។

ក្រុមហ៊ុន **ហ្វឺស-ក្លាស សឹលូសិន អិលធីឌី** ចុះបញ្ជីពាណិជ្ជកម្មក្រោមលេខ Co. 13113/09P នៅក្រសួងពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា
#៨ មហាវិថីព្រះសីហនុ ភ្នំពេញ កម្ពុជា។ ទូរស័ព្ទ/ទូរសារ៖ (៨៥៥) ២៣ ២១៤ ១៤២ - ទូរស័ព្ទដៃ៖ ០១២ ៩២៥ ៧៥៩ / ០១៨ ៨០១ ៣៧៧ I info@firstclass.com.kh I www.firstclass.com.kh
ក្រុមហ៊ុនសូមបញ្ជាក់ថាសំណៅបកប្រែនេះពិតជាត្រឹមត្រូវតាមឯកសារភ្ជាប់ចំពោះគ្រប់ខ្លឹមសារមូលដ្ឋានទាំងអស់ ភ្នំពេញ ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៣
ប្រាកដមែន ។ សេចក្តីបញ្ជាក់នេះពុំបានកំណត់អំពីយថាភាពនៃច្បាប់ដើម ឬអំពីភាពត្រឹមត្រូវនៃព័ត៌មានដែលបានរៀបរាប់នៅក្នុងសំណៅនេះឡើយ ។ *(USEmbassy2013)*
**លឹម គ្រុយ អគ្គនាយក**
**ក្រុមហ៊ុន ហ្វឺស-ក្លាស សឹលូសិន អិលធីឌី**

ជ.	ការឆ្លើយតបចំពោះសំណួររបស់អ្នកចូលរួម

អ្នកប្រមូលទិន្នន័យនឹងជួបមនុស្សជាច្រើនដែលនឹងមានសំណួរអំពីការសិក្សា រួមមានអ្នកនឹងចូលរួម អ្នកបានចូលរួម និងអ្នកឈរមើលផ្សេងទៀតដែលមិនពាក់ព័ន្ធក្នុងការសិក្សា។ មនុស្សមួយចំនួននឹងមិនយល់អ្វីដែលហៅថា "ការស្រាវជ្រាវ" ឬមិនដឹងកិច្ចការរបស់អ្នកស្រាវជ្រាវដែលនឹងដឹកនាំក្នុងគម្រោងនេះឡើយ។ ដូច្នេះអ្នកចូលរួមក្នុងការសិក្សាអាចសួរសំណួរគ្រប់ប្រភេទ ដែលក្នុងចំណោមនោះសំណួរមួយចំនួនមិនពាក់ព័ន្ធទៅនឹងនីតិវិធីសិក្សាឡើយ។

អ្នកអង្កេតតាមដាននឹងធ្វើការបណ្តុះបណ្តាលដល់អ្នកប្រមូលទិន្នន័យ ដើម្បីបង្ហាញនូវបញ្ហាជាច្រើនដែលអ្នកចូលរួមអាចនឹងលើកឡើង។ នេះគឺដោយសារតែនៅតំបន់ក្នុងមូលដ្ឋានជាប្រចាំមួយ អ្នកប្រមូលទិន្នន័យ គឺជាអ្នកតំណាងឲ្យការសិក្សា ពេលពិភាក្សាជាមួយអ្នកចូលរួម និងសហគមន៍ទាំងមូល។ វាជាការសំខាន់ដែលអ្នកប្រមូលទិន្នន័យត្រូវបង្ហាញការគោរពដ៏ត្រឹមត្រូវដល់អ្នកចូលរួមទាំងអស់ និងប្រឹងប្រែងឲ្យអស់ពីសមត្ថភាពដើម្បីឆ្លើយតបទៅនឹងបញ្ហានានា។ អ្នកប្រមូលព័ត៌មានត្រូវមានភាពអត់ធ្មត់ និងឆ្លើយតបរាល់សំណួរដែលអ្នកចូលរួមសួរតាមលទ្ធភាពខ្លួនដែលអាចឆ្លើយបាន។ អ្នកប្រមូលទិន្នន័យ មិនត្រូវឆ្លើយនឹងសំណួរណាមួយដែលខ្លួនមិនដឹងចម្លើយច្បាស់លាស់ឡើយ ពីព្រោះការផ្តល់ព័ត៌មានមិនត្រឹមត្រូវអាចនាំឲ្យមានផលប៉ះពាល់កាន់តែអាក្រក់ជាងការមិនផ្តល់ចម្លើយ។ ប្រសិនបើអ្នកគឺជាអ្នកប្រមូលទិន្នន័យ ហើយអ្នកចូលរួមសួរសំណួរ ប៉ុន្តែអ្នកមិនប្រាកដអំពីចម្លើយ ហើយតទៅនេះជាអ្វីដែលអ្នកគួរធ្វើ៖ អ្នកគួរប្រាប់អ្នកចូលរួមថាអ្នកមិនមានចម្លើយច្បាស់លាស់ចំពោះសំណួរនោះទេ ហើយអ្នកនឹងសួរសំណួរនោះទៅកាន់ប្រធានគម្រោងសិក្សា ហើយអ្នកនឹងផ្តល់ចម្លើយដល់គាត់វិញនៅពេលទទួលបានចម្លើយពីប្រធានគម្រោងសិក្សា។ ការធ្វើបែបនេះមានសារសំខាន់ណាស់ ពីព្រោះវាជាទង្វើមួយសបញ្ជាក់ឲ្យឃើញអំពីការគោរពរបស់អ្នកចំពោះអ្នកចូលរួម និងមានភាពប្រាកដផងដែរថាព័ត៌មានដែលអ្នកផ្តល់ជូនអ្នកចូលរួមគឺមានភាពសុក្រឹត។ នៅពេលអ្នកគិតថា អ្នកចូលរួមមិនមានសំណួរបន្ថែមទៀតទេនោះ អ្នកអាចសួរថា "តើអ្នកទាំងអស់គ្នាមានសំណួរផ្សេងទៀតដែរឬទេ?" ដើម្បីបញ្ជាក់ថាសំណួរទាំងអស់ត្រូវបានឆ្លើយតបរួចរាល់។ ប្រសិនបើពុំមានសំណួរបន្ថែមទៀតទេនោះ អ្នកអាចធ្វើការបន្ត។

## ២.	**ភាពត្រឹមត្រូវនៃទិន្នន័យ**

ក.	ការគោរពតាមវិទ្យាសាស្ត្រនៃការសិក្សា

ទិន្នន័យគឺជា "លទ្ធផល" នៃការស្រាវជ្រាវ។ វាជាការសំខាន់ណាស់ដែលអ្នកប្រមូលទិន្នន័យត្រូវប្រមូល កត់ត្រា និងរក្សាទុកទិន្នន័យឲ្យបានត្រឹមត្រូវ។ អ្នកវិទ្យាសាស្ត្រនឹងប្រើប្រាស់ទិន្នន័យទាំងនេះដើម្បីឆ្លើយនឹងសំណួរស្រាវជ្រាវដែលបានកំណត់នៅក្នុងផែនការគម្រោង។ ប្រសិនបើទិន្នន័យទាំងនោះ ជាទិន្នន័យមិនត្រឹមត្រូវ លទ្ធផលដែលអ្នកវិទ្យាសាស្ត្រផ្តល់ឲ្យក៏នឹងមិនត្រឹមត្រូវទៅតាមនោះផងដែរ។ មនុស្សដែលរស់រានមានជីវិតអាចប៉ះពាល់ដោយសារលទ្ធផលនៃការសិក្សា ដោយប្រឈមនឹងហានិភ័យដោយសារតែលទ្ធផល និងសកម្មភាពអនុវត្តមិនត្រឹមត្រូវ។ ដូច្នេះជាការសំខាន់ខ្លាំងណាស់ដែលថាគ្រប់ពេលទាំងអស់ទិន្នន័យត្រូវបានប្រមូល កត់ត្រា និងរក្សាទុកបានយ៉ាងត្រឹមត្រូវ។ អ្វីដែលសំខាន់នោះគឺថា ប្រសិនបើអ្នកធ្វើឲ្យមានកំហុសឆ្គងណាមួយក្នុងការបំពេញកិច្ចការទាំងនេះ អ្នកត្រូវប្រាប់អ្នកគ្រប់គ្រងរបស់អ្នកភ្លាមៗ


សិទ្ធិគតចម្លងឆ្នាំ២០១០ ដោយសាកលវិទ្យាល័យ Johns Hopkins។ រក្សាសិទ្ធិគ្រប់យ៉ាង។

ហ្វឺស-ក្លាស FIRST-CLASS
ក្រុមហ៊ុន **ហ្វឺស-ក្លាស សឹលូសិន អិលធីឌី** ចុះបញ្ជីពាណិជ្ជកម្មក្រោមលេខ Co. 13113/09P នៅក្រសួងពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា
#៨ មហាវិថីព្រះសីហនុ ភ្នំពេញ កម្ពុជា។ ទូរស័ព្ទ/ទូរសារ៖ (៨៥៥) ២៣ ២១៤ ១៤២ - ទូរស័ព្ទដៃ៖ ០១២ ៩២៥ [illegible] | info@firstclass.com.kh | www.firstclass.com.kh
ក្រុមហ៊ុនសូមបញ្ជាក់ថាសំណៅបកប្រែនេះពិតជាត្រឹមត្រូវតាមឯកសារភ្ជាប់ចំពោះគ្រប់ខ្លឹមសារមូលដ្ឋានទាំងអស់ ភ្នំពេញ ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៣
ប្រាកដមែន ។ សេចក្តីបញ្ជាក់នេះពុំបានកំណត់អំពីយថាភាពនៃច្បាប់ដើម ឬអំពីភាពត្រឹមត្រូវនៃព័ត៌មានដែលបាន **លឹម គ្រួយ អគ្គនាយក**
រៀបរាប់នៅក្នុងសំណៅនេះឡើយ ។ *(USEmbassy2013)* **ក្រុមហ៊ុន ហ្វឺស-ក្លាស សឹលូសិន អិលធីឌី**
FIRST-CLASS SOLUTIONS LTD.

ដើម្បីឲ្យអ្នកអង្កេត ឬប្រធានក្រុមស្រាវជ្រាវដឹងអំពីបញ្ហានេះ។ ពួកគាត់អាចដោះស្រាយបញ្ហាបាន ឬដឹងថាទិន្នន័យមួយចំនួនអាចនឹងមិនប្រើប្រាស់។

ខ. ការប្រមូល ការកត់ត្រា និងការរក្សាទុកទិន្នន័យសិក្សា

ផែនការស្រាវជ្រាវបង្ហាញពីគោលបំណងនៃគម្រោង និងវិធីសាស្ត្រដែលក្រុមស្រាវជ្រាវនឹងសម្រេចបានគោលបំណងសិក្សាទាំងនេះ។ ព័ត៌មានលម្អិតអំពីការប្រមូលទិន្នន័យ និងការកត់ត្រាទិន្នន័យសិក្សាត្រូវបានដាក់បញ្ចូល ហើយជាទូទៅឯកសារណែនាំអំពីដំណើរការសិក្សា មានសេចក្តីលម្អិតបន្ថែមអំពីកិច្ចការទាំងឡាយដែលនឹងត្រូវធ្វើ។ អ្នកប្រមូលទិន្នន័យត្រូវយល់ឲ្យច្បាស់អំពីរបៀបដែលគួរប្រមូល និងរបៀបកត់ត្រាទិន្នន័យ។ អ្នកដឹកនាំក្រុមសិក្សាស្រាវជ្រាវនឹងបណ្តុះបណ្តាលអ្នកប្រមូលទិន្នន័យអំពីដំណើរការ។ ប្រសិនបើអ្នកប្រមូលទិន្នន័យមានចម្ងល់ ពួកគាត់មិនត្រូវខ្លាចក្នុងការសាកសួរឡើយ។ ជាការពិតណាស់ ប្រសិនបើអ្នកប្រមូលទិន្នន័យមិនសួរសំណួរ នៅពេលខ្លួនមិនប្រាកដពីរបៀបធ្វើការងារនោះ ពួកគាត់មិនអាចប្រាកដថាទិន្នន័យដែលខ្លួនប្រមូលបាននោះត្រឹមត្រូវឡើយ។

នៅពេលបញ្ចប់ការបណ្តុះបណ្តាល អ្នកប្រមូលទិន្នន័យនឹងចាប់ផ្តើមការងាររបស់ខ្លួន។ ការប្រមូលបានទិន្នន័យល្អមានន័យថា ការអនុវត្តតាមការណែនាំ និងការបំពេញនៅលើក្រដាសប្រមូលទិន្នន័យប្រកបដោយភាពសុក្រឹត។ ព័ត៌មានកត់ត្រាត្រឹមត្រូវ គឺត្រូវតែប្រាកដថារាល់ចម្លើយដែលបានសរសេរអាចអាន និងមើលឃើញច្បាស់។ អ្នកប្រមូលទិន្នន័យត្រូវកត់ត្រាព័ត៌មានដោយស្មោះត្រង់ និងមានសុក្រិតភាព។ ព័ត៌មានផ្សេងទៀតដែលមិនបានបញ្ជាក់នៅលើក្រដាសកម្រងសំណួរ មិនត្រូវសរសេរបញ្ចូលឡើយ។ ឧទាហរណ៍ ប្រសិនបើពុំមានចន្លោះសម្រាប់បំពេញ "ឈ្មោះ" ឬ "អាសយដ្ឋាន" ទេនោះ ទិន្នន័យទាំងនេះមិនគួរកត់ត្រានៅលើក្រដាសប្រមូលទិន្នន័យឡើយ។ មិនគួរ "បង្កើត" ព័ត៌មាន និងកត់ត្រានៅក្នុងសន្លឹកប្រមូលទិន្នន័យឡើយ។

ការរក្សាទុកទិន្នន័យត្រឹមត្រូវមានន័យថា វិធានការសុវត្ថិភាពទាំងអស់ត្រូវបានអនុវត្តនៅពេលដឹកជញ្ជូន (ផ្ទេរ) ទិន្នន័យទៅកាន់កន្លែងរក្សាទុកចុងក្រោយ។ អ្នកប្រមូលទិន្នន័យមិនគួរដាក់ឯកសារទិន្នន័យនៅកន្លែងដែលអាចបាត់បង់ អាចត្រូវគេលួច ឬអ្នកផ្សេងក្រៅពីក្រុមសិក្សាស្រាវជ្រាវអាចអានបានឡើយ។ អ្នកប្រមូលទិន្នន័យគួរផ្តល់ឯកសារទិន្នន័យដល់អ្នកដែលទទួលខុសត្រូវក្នុងការរក្សាទុក ហើយអ្នករក្សាទិន្នន័យនោះគួរអនុវត្តតាមការណែនាំទាំងអស់ ដើម្បីការពារព័ត៌មានសម្ងាត់ផ្ទាល់ខ្លួនរបស់បុគ្គលឲ្យបានខ្ជាប់ខ្ជួន។ ប្រសិនបើទិន្នន័យត្រូវប្រមូលតាមប្រព័ន្ធអេឡិចត្រូនិក គោលការណ៍ និងច្បាប់ដូចគ្នាត្រូវអនុវត្តតាមដោយភាពស្មោះត្រង់ ការការពារ និងដោយយកចិត្តទុកដាក់។

គ. ការងាកចេញពីនីតិវិធីសិក្សា

ពេលខ្លះអ្នកប្រមូលទិន្នន័យមិនអាចអនុវត្តតាមនីតិវិធីសិក្សាដោយសារមិនមែនកំហុសផ្ទាល់របស់ខ្លួនឡើយ ហើយពេលខ្លះទៀត អ្នកប្រមូលទិន្នន័យផ្ទាល់អាចធ្វើឲ្យមានកំហុសឆ្គងដោយខ្លួនឯងផងដែរ។ កត្តាសំខាន់បំផុតនោះគឺ អ្នកប្រមូលទិន្នន័យត្រូវប្រាប់អ្នកដឹកនាំការស្រាវជ្រាវឲ្យដឹងអំពីបញ្ហានេះ ពីព្រោះអ្នកដឹកនាំគម្រោងស្រាវជ្រាវគឺជាអ្នកទទួលខុសត្រូវក្នុងការរាយការណ៍បញ្ហាជូនស្ថាប័នក្រមសីលធម៌ (IRB) ដើម្បីធ្វើការត្រួតពិនិត្យ។ មិនមែនជារឿងអាម៉ាស់មុខនោះទេក្នុងការរាយការណ៍បញ្ហាទាំងនេះ។ បញ្ហាទាំងនេះ



សិទ្ធិថតចម្លងឆ្នាំ២០១០ ដោយសាកលវិទ្យាល័យ Johns Hopkins។ រក្សាសិទ្ធិគ្រប់យ៉ាង។

ក្រុមហ៊ុន **ហ្វើស-ក្លាស សឹលូសិន អិលធីឌី** ចុះបញ្ជីពាណិជ្ជកម្មក្រោមលេខ Co. 13113/09P នៅក្រសួងពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា
#៨ មហាវិថីព្រះសីហនុ ភ្នំពេញ កម្ពុជា។ ទូរស័ព្ទ/ទូរសារ៖ (៨៥៥) ២៣ ២១៤ ១៩២ - ទូរស័ព្ទដៃ៖ ០១២ ៩២៥ ៧៨៩ / ០១៨ ៩០១ ៣៧៧ | info@firstclass.com.kh | www.firstclass.com.kh
ក្រុមហ៊ុនសូមបញ្ជាក់ថាសំណៅបកប្រែនេះពិតជាត្រឹមត្រូវតាមឯកសារភ្ជាប់ចំពោះគ្រប់ខ្លឹមសារមូលដ្ឋានទាំងស្រុង ភ្នំពេញ ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៣
ប្រាកដមែន ។ សេចក្តីបញ្ជាក់នេះពុំបានកំណត់អំពីយថាភាពនៃច្បាប់ដើម ឬអំពីភាពត្រឹមត្រូវនៃព័ត៌មានដែលបាន **លឹម គ្រុយ អគ្គនាយក**
រៀបរាប់នៅក្នុងសំណៅនេះឡើយ ។ *(USEmbassy2013)* **ក្រុមហ៊ុន ហ្វើស-ក្លាស សឹលូសិន អិលធីឌី**

អាចកើតមានឡើងគ្រប់ពេលទាំងអស់។ បើមិនដូច្នោះទេ វាមិនមែនជាការល្អឡើយ ប្រសិនបើអ្នកប្រមូលទិន្នន័យមិនបានរាយការណ៍អំពីបញ្ហាទាំងនេះ ដោយសារមានមូលហេតុថាទិន្នន័យទាំងនោះមិនល្អ ឬថាអ្នកចូលរួមមានបញ្ហាជាមួយនឹងការសិក្សាស្រាវជ្រាវនេះ។ ហើយក៏មានន័យផងដែរថាអ្នកដឹកនាំការស្រាវជ្រាវនឹងមិនអាចបំពេញរបាយការណ៍ជូន IRB បាន។

អ្នកប្រមូលទិន្នន័យល្អ គឺជាអ្នកដែលមានការប្រាស្រ័យទាក់ទងជាមួយប្រធានគ្រប់គ្រងរបស់ខ្លួនអំពីបញ្ហាទាំងនេះ និងឲ្យប្រធានគ្រប់គ្រងរបស់ខ្លួនជាអ្នកសម្រេចចិត្តលើវិធានការដែលត្រូវអនុវត្ត។


សិទ្ធិថតចម្លងឆ្នាំ២០១០ ដោយសាកលវិទ្យាល័យ Johns Hopkins។ រក្សាសិទ្ធិគ្រប់យ៉ាង។

ហ្វើស-ក្លាស FIRST-CLASS
In Pursuit of Speed and Quality
ក្រុមហ៊ុន **ហ្វើស-ក្លាស សឹលូសិន អិលធីឌី** ចុះបញ្ជីពាណិជ្ជកម្មក្រោមលេខ Co. 13113/09P នៅក្រសួងពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា
#៨ មហាវិថីព្រះសីហនុ ភ្នំពេញ កម្ពុជា। ទូរស័ព្ទ/ទូរសារ៖ (៨៥៥) ២៣ ២១៤ ១៤២ - ទូរស័ព្ទដៃ៖ ០១២ ៩២៥ ៧៨៩ / ០១៨ ៩០១ ៣៧៧ I info@firstclass.com.kh I www.firstclass.com.kh
ក្រុមហ៊ុនសូមបញ្ជាក់ថាសំណៅបកប្រែនេះពិតជាត្រឹមត្រូវតាមឯកសារភ្ជាប់ចំពោះគ្រប់ខ្លឹមសារមូលដ្ឋានទាំងអស់ ប្រាកដមែន ។ សេចក្តីបញ្ជាក់នេះពុំបានកំណត់អំពីយថាភាពនៃច្បាប់ដើម ឬអំពីភាពត្រឹមត្រូវនៃព័ត៌មានដែលបាន រៀបរាប់នៅក្នុងសំណៅនេះឡើយ ។ *(USEmbassy2013)*
ភ្នំពេញ ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៣
**លឹម គ្រុយ អគ្គនាយក**
**ក្រុមហ៊ុន ហ្វើស-ក្លាស សឹលូសិន អិលធីឌី**
FIRST-CLASS SOLUTIONS LTD.